**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ០០៧/០២/២០០៦.កបធ

**សូមក្រាបថ្វាយបង្គំទូល**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

សូមទ្រង់ព្រះមេត្តាជ្រាប ។

**<u>កម្មវត្ថុ</u>** : សេចក្តីថ្វាយមតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ អំពីសេចក្តីព្រាងច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ។

**<u>យោង</u>** : ព្រះរាជសារ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៦

ទូលព្រះបង្គំយើងខ្ញុំ ជាប្រធាន និងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលព្រះរាជសារដូចមានយោងខាងលើ បានរួមប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ ហើយបានឯកភាពលើកមតិដើម្បីក្រាបថ្វាយបង្គំទូលព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលមានខ្លឹមសារដូចតទៅ ៖

១-សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ សំដៅកែប្រែខ្លឹមសារមាត្រា ៨២ មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងខ្លឹមសារមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែម ដោយសម្រុតមតិភាគច្រើនពីរភាគបី ឱ្យចុះមកត្រឹមមតិភាគច្រើនដាច់ខាត ។ ព្រមជាមួយនេះ ក៏បានកែសម្រួលកូរ៉ុមសម្រាប់ប្រជុំរដ្ឋសភាចែងក្នុងមាត្រា ៨៨ថ្មី និងសម្រាប់ប្រជុំព្រឹទ្ធសភា ចែងក្នុងមាត្រា ១១១ថ្មី(មួយ) ។

មាត្រា ១៥១ ថ្មី (មាត្រា ១៣២ ចាស់) នៃរដ្ឋធម្មនុញ្ញបានចែងថា "ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។ ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។"

មាត្រា ១៥២ ថ្មី (មាត្រា ១៣៣ ចាស់) នៃរដ្ឋធម្មនុញ្ញបានចែងថា " ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឱ្យធ្វើនៅពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។"

មាត្រា ១៥៣ ថ្មី (មាត្រា ១៣៤ ចាស់) នៃរដ្ឋធម្មនុញ្ញបានចែងថា "ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ មិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរី ពហុបក្ស និង របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។"

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail:sgcc@camnet.com.kh

តាមការពិនិត្យលើសេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះ ឃើញថា ពុំមានអ្វីប៉ះពាល់ដល់លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និង របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញឡើយ ។ ម្យ៉ាងទៀត ការស្នើធ្វើវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ធ្វើឡើងក្នុងកាលៈទេសៈធម្មតារបស់ប្រទេសជាតិ ។

២-ក្រុមប្រឹក្សាធម្មនុញ្ញ យល់ឃើញថា ការធ្វើវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ អាចធ្វើបាន ។

សូមក្រាបថ្វាយបង្គំទូល ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ជាទីបំផុត ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស ។

ក្រាបថ្វាយបង្គំទូល នៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៉ិន ឃិន